ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាឧទ្ធរណ៍ភ្នំពេញ
សំណុំរឿងព្រហ្មទណ្ឌ
លេខ ២៨៩/១៨-៣-២០១៣
សាលដីកា
លេខ ៩៨ ក្រ"ណ"/៣១-១២-១៣

## តាងនាមប្រជារាស្ត្រខ្មែរ
## សាលាឧទ្ធរណ៍ភ្នំពេញ

បង្កើតឡើងតាមច្បាប់ស្តីពីការចាត់តាំង និងសកម្មភាពរបស់សាលាជម្រះក្តីដែលប្រកាសឲ្យប្រើតាមក្រឹត្យលេខ ០៦ ក្រ ចុះថ្ងៃទី ០៨-០២-១៩៩៣ បានបើកសវនាការជាសាធារណៈនៅសាលាឧទ្ធរណ៍នាថ្ងៃទី ១៨-១២-២០១៣ (៨ម៉ោង០០) ដែលមានសមាសភាពដូចខាងក្រោម ៖

**ក្រុមប្រឹក្សាជំនុំជម្រះ**

លោក [redacted] ជាប្រធាន
លោក [redacted] ជាចៅក្រមប្រឹក្សា
លោក [redacted] ជាចៅក្រមប្រឹក្សា

**តំណាងមហាអយ្យការ**

លោក [redacted] ជាព្រះរាជអាជ្ញា

**ក្រឡាបញ្ជីសវនាការ**

លោក [redacted]

ដើម្បីជំនុំជម្រះលើសំណុំរឿងព្រហ្មទណ្ឌលេខ ២៨៩ ចុះថ្ងៃទី ១៨-៣-២០១៣ របស់សាលាឧទ្ធរណ៍ ដែលមាន ៖

**-ជនជាប់ចោទឈ្មោះ [redacted] សុគន់** ភេទប្រុស អាយុ ១៩ ឆ្នាំ ជាតិខ្មែរ មុខរបរ គ្មាន កើតនៅសង្កាត់បឹងព្រលិត ខណ្ឌ៧មករា រាជធានីភ្នំពេញ ទីលំនៅមុនពេលឃុំខ្លួន ស្នាក់នៅបន្ទប់ជួលលេខ [redacted] ។ ឪពុកឈ្មោះ [redacted] "រ" ម្តាយឈ្មោះ [redacted] "រ" នៅលីវ ទោសពីមុន **ធ្លាប់ជាប់ពន្ធនាគារព្រៃ ស ចំនួន ៥ (ប្រាំបួន) ខែ ពីបទ បង្ខាំងមនុស្សខុសច្បាប់, ប្រើប្រាស់អាវុធខុសច្បាប់ និងប្រើប្រាស់គ្រឿងញៀន (ប្តឹងឧទ្ធរណ៍)។**

ឃុំខ្លួននៅពន្ធនាគារព្រៃ ស "ម១" តាមដីកាបង្គាប់ឲ្យឃុំខ្លួនលេខ ១០៥៥ ត.ព្រ ចុះថ្ងៃទី **២៧-៦-២០១២** របស់សាលាដំបូងរាជធានីភ្នំពេញ (ឯកសារលេខ ៦) ។

មានលោក [redacted] **ទិមុល** ជាមេធាវីការពារសិទ្ធិជនជនាប់ចោទ ។

**ជាប់ចោទពីបទ៖ លួចមានស្ថានទម្ងន់ទោស** ប្រព្រឹត្តនៅចំណុចមុខផ្ទះលេខ ៥៨ C ផ្លូវលេខ ៣៧៦ ក្រុម ៥២ ភូមិ ១ សង្កាត់បឹងកេងកង ៣ ខណ្ឌចំការមន រាជធានី



Scanned with CamScanner

ភ្នំពេញ កាលពីថ្ងៃទី ១៨-៦-២០១២ ។ បទល្មើសព្រហ្មទណ្ឌដែលមានចែង ឲ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៣៥៣ និងមាត្រា ៣៥៧ នៃក្រមព្រហ្មទណ្ឌ

-ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] រដ្ឋា ភេទប្រុស អាយុ ២៤ ឆ្នាំ ជាតិខ្មែរ មុខរបរនិស្សិត ទីលំនៅសព្វថ្ងៃផ្ទះលេខ [redacted] ។

## ឯវៀងហេតុមានដូចតទៅ

**សកម្មភាព**ប្រព្រឹត្តរបស់ជនជាប់ចោទមានដូចខាងក្រោម ៖

កាលពីថ្ងៃទី ១៨-៦-២០១២ វេលាម៉ោង ២២.៤៥ នាទី ជនរងគ្រោះឈ្មោះ [redacted] រដ្ឋា បាន ជិះម៉ូតូម៉ាកស្កុបពី ពណ៌ស-ខ្មៅ ផលិតឆ្នាំ ២០១១ ពាក់ស្លាកលេខ ភ្នំពេញ 1AW-7787 លេខតួ និងលេខម៉ាស៊ីន ០១៥៨០៧២ មកដល់ចំណុចផ្ទះលេខ ៤៨ C ផ្លូវលេខ ៣៧៦ ក្រុម ៥២ ភូមិ ១ សង្កាត់បឹងកេងកង ៣ ខណ្ឌចំការមន រាជធានីភ្នំពេញ ក៏ឈប់និយាយទូរស័ព្ទ ហើយស្រាប់តែមាន ជនល្មើសឈ្មោះ [redacted] សុគង់, ឈ្មោះ ឆាយ និងឈ្មោះ នៃ ជិះម៉ូតូមួយគ្រឿងម៉ាក C 125 ពណ៌ ខ្មៅ ផលិតឆ្នាំ ២០១២ ដោយឈ្មោះ ឆាយ ជាអ្នកបើកម៉ូតូបុកជនរងគ្រោះឲ្យដួល រួចឈ្មោះ នៃ បានដកកាំភ្លើងខ្លី K 59 ភ្ជង់ជនរងគ្រោះឲ្យបែរមុខចេញ ហើយឈ្មោះ [redacted] សុគង់ បានស្ទុះទៅ ឆក់យកទូរស័ព្ទពីដៃជនរងគ្រោះ និងលើកម៉ូតូជនរងគ្រោះជិះទៅលាក់ទុកក្នុងបន្ទប់ជួល ។ បន្ទាប់ មកឈ្មោះ [redacted] សុគង់ បានយកម៉ូតូនោះ ទៅលក់ឲ្យឈ្មោះ ឆេង បានប្រាក់ចំនួន ៧០០ ដុល្លារ ចំណែកឈ្មោះ ឆាយ និងឈ្មោះ នៃ បានយកទូរស័ព្ទជនរងគ្រោះគេចខ្លួនបាត់ ។

**បានឃើញ**សាលក្រមព្រហ្មទណ្ឌលេខ ០៩ "កប៤" ចុះថ្ងៃទី ៣១-០១-១៣ របស់សាលា ដំបូងរាជធានីភ្នំពេញ ដែលមានខ្លឹមសារនៃសេចក្តីសម្រេចដូចតទៅ ៖

១-ផ្តន្ទាទោសជនជាប់ចោទឈ្មោះ [redacted] សុគង់ ភេទប្រុស អាយុ ១៩ ឆ្នាំ ជាតិខ្មែរ ដាក់ ពន្ធនាគារកំណត់រយៈពេល ០៥ (ប្រាំ) ឆ្នាំ ពីបទ លួចមានស្ថានទម្ងន់ទោស ប្រព្រឹត្តនៅចំណុចមុខ ផ្ទះលេខ ៤៨ C ផ្លូវលេខ ៣៧៦ ក្រុម ៥២ ភូមិ ១ សង្កាត់បឹងកេងកង ៣ ខណ្ឌចំការមន រាជធានី ភ្នំពេញ កាលពីថ្ងៃទី ១៨-៦-២០១២ តាមមាត្រា ៣៥៣ និងមាត្រា ៣៥៧ នៃក្រមព្រហ្មទណ្ឌ ។

២-បង្គាប់ឲ្យជនជាប់ចោទឈ្មោះ [redacted] សុគង់ សងសំណងថ្លៃសម្ភារៈដែលបាត់បង់ឲ្យទៅ ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] រដ្ឋា ចំនួន ២.៥០០ (ពីរពាន់ប្រាំរយ) ដុល្លារអាមេរិក និងជម្ងឺចិត្ត ចំនួន ១.០០០.០០០ (មួយលាន) រៀល ។ ច្រានចោលការទាមទារលើសពីនេះ ។

៣-សាលក្រមនេះជំនុំជម្រះនៅថ្ងៃទី ១៧-០១-២០១៣ និងប្រកាសជាសាធារណៈនៅថ្ងៃទី ៣១-០១-២០១៣ ចំពោះមុខជនជាប់ចោទ, ដើមបណ្តឹងរដ្ឋប្បវេណី, មេធាវីការពារសិទ្ធិឲ្យជនជាប់ ចោទ បើកសិទ្ធិប្តឹងឧទ្ធរណ៍ក្នុងកំណត់ច្បាប់ ។

**បានឃើញ**ពាក្យបណ្តឹងឧទ្ធរណ៍លេខ១៦៦ ចុះថ្ងៃទី២៨-០២-២០១៣ របស់ជនជាប់ចោទ ឈ្មោះ [redacted] សុគង់ ប្តឹងឧទ្ធរណ៍និងសាលក្រមព្រហ្មទណ្ឌលេខ ០៩ "កប៤" ចុះថ្ងៃទី ៣១-០១-១៣ របស់សាលាដំបូងរាជធានីភ្នំពេញ លើចំណុចនៃសេចក្តីសម្រេចទាំងមូល ។



Scanned with CamScanner

**បានឃើញ**របាយការណ៍រឿង ចុះថ្ងៃទី ២០-៦-២០១៣ របស់ចៅក្រមរបាយការណ៍សាលាឧទ្ធរណ៍ ។

**បានឃើញ**សេចក្ដីសន្និដ្ឋាន ចុះថ្ងៃទី ១៩-៧-២០១៣ របស់តំណាងមហាអយ្យការអមសាលាឧទ្ធរណ៍ ។

<u>នាពេលសវនាការ</u>

-ប្រធានក្រុមប្រឹក្សាជំនុំជម្រះអានសង្ខេបរបាយការណ៍រឿង

**-ជនជាប់ចោទឈ្មោះ** [redacted] **សុគង់** ឆ្លើយថា ចំពោះសកម្មភាពនោះ ខ្លួនពិតជាបានប្រព្រឹត្តមែន ប៉ុន្តែចំពោះកាំភ្លើង គឺមិនមែនជារបស់ខ្លួនទេ ។ ខ្លួនសំណូមពរសុំឲ្យសាលាឧទ្ធរណ៍មេត្តាបន្ធូរបន្ថយទោសដល់ខ្លួនផង ។

**-តំណាងមហាអយ្យការធ្វើសេចក្ដីសន្និដ្ឋានថា** ពាក់ព័ន្ធនឹងអង្គហេតុនេះ ជាប់ចោទបានឆ្លើយសារភាពទទួលស្គាល់កំហុសរបស់ខ្លួនហើយ តែបានបដិសេធចំពោះកាំភ្លើងថា មិនមែនជារបស់ខ្លួន (ជនជាប់ចោទ) ទេ ដូច្នេះ សុំឲ្យក្រុមប្រឹក្សាពិចារណា និងសម្រេចតម្កល់តាមច្បាប់ ។

**-មេធាវីការពារសិទ្ធិជនជាប់ចាប់ចោទធ្វើសេចក្ដីសន្និដ្ឋានថា** រឿងនេះ កូនក្ដីខ្លួនបានឆ្លើយសារភាពអំពីសកម្មភាពរបស់ខ្លួន (ជនជាប់ចោទ) តែបានបដិសេធចំពោះកាំភ្លើងនោះ គឺមិនមែនជារបស់ខ្លួនឡើយ ហេតុដូច្នេះ សុំឲ្យតុលាការពិចារណាសម្រេចតាមមាត្រា ៣៥៣, ៣៥៦ ។

-ក្រោយពីបានស្ដាប់អំណានរបាយការណ៍រឿង

-ក្រោយពីបានស្ដាប់ចម្លើយរបស់ជនជាប់ចោទ

-ក្រោយពីបានស្ដាប់សេចក្ដីសន្និដ្ឋានរបស់តំណាងមហាអយ្យការ

-ក្រោយពីបានស្ដាប់សេចក្ដីសន្និដ្ឋានរបស់មេធាវីជនជាប់ចោទ

-ក្រោយពីបានពិនិត្យភស្តុតាងដែលពាក់ព័ន្ធនឹងរឿងក្ដី

-ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ

<u>សាលាឧទ្ធរណ៍យល់ឃើញថា</u>

១-ពាក្យបណ្ដឹងឧទ្ធរណ៍លេខ ១៦៦ ចុះថ្ងៃទី ២៨-០២-២០១៣ របស់ជនជាប់ចោទឈ្មោះ [redacted] **សុគង់** ប្ដឹងឧទ្ធរណ៍នឹងសាលក្រមព្រហ្មទណ្ឌលេខ ០៩ "កប៥" ចុះថ្ងៃទី ៣១-០១-២០១៣ របស់សាលាដំបូងរាជធានីភ្នំពេញ ត្រង់ចំណុចទាំងមូលនៃសេចក្ដីសម្រេច បានធ្វើឡើងត្រឹមត្រូវតាមកំណត់ច្បាប់ យោងតាមមាត្រា ៣៧៣, មាត្រា ៣៧៥, មាត្រា ៣៧៦ និងមាត្រា ៣៨២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ដែលអាចឲ្យសាលាឧទ្ធរណ៍ទទួលយកសំណុំរឿងព្រហ្មទណ្ឌលេខ ២៨៩ ចុះថ្ងៃទី ១៨-៣-២០១៣ របស់សាលាឧទ្ធរណ៍ មកធ្វើការជំនុំជម្រះបាន ។

២-នាពេលសវនាការជនជាប់ចោទឈ្មោះ [redacted] **សុគង់** បានឆ្លើយសារភាពថា ខ្លួនពិតជាបានធ្វើសកម្មភាពយកកាំភ្លើងភ្ជង់ជនរងគ្រោះ ហើយយកម៉ូតូជនរងគ្រោះប្រាកដមែន ។ ការដែលខ្លួនប្ដឹងឧទ្ធរណ៍នឹងសាលក្រមរបស់សាលាដំបូង គឺចង់សុំឲ្យសាលាឧទ្ធរណ៍បន្ធូរបន្ថយទោស ។



Scanned with CamScanner

សំណើរបស់ជនជាប់ចោទ សាលាឧទ្ធរណ៍ពុំអាចលើកយកមកពិចារណាបានទេ សកម្មភាពរបស់ជនជាប់ចោទមានគ្រោះថ្នាក់ធ្ងន់ធ្ងរដល់សណ្តាប់ធ្នាប់សាធារណៈ និង សង្គម ហើយទណ្ឌកម្មដែលផ្តន្ទាទោសលើជនជាប់ចោទរយៈពេល ០៥ (ប្រាំ) ឆ្នាំ មានលក្ខណៈសមស្របទៅនឹងអំពើរបស់ជនជាប់ចោទ ហេតុដូច្នេះឃើញថា សំអាងហេតុ និងសេចក្តីសម្រេចក្នុងសាលក្រមព្រហ្មទណ្ឌលេខ ០៩ "កប៤" ចុះថ្ងៃទី ៣១-០១-២០១៣ របស់សាលាដំបូងរាជធានីភ្នំពេញ មានមូលហេតុត្រឹមត្រូវ គប្បីសាលាឧទ្ធរណ៍តម្កល់សាលក្រមនេះ ទុកជាបានការ ។

៣-តំណាងមហាអយ្យការធ្វើសេចក្តីសន្និដ្ឋានថា ជនជាប់ចោទបានឆ្លើយសារភាព ដូច្នេះសុំឲ្យក្រុមប្រឹក្សាសម្រេចតម្កល់សាលក្រមរបស់សាលាដំបូង ទុកជាបានការ ។

៤-មេធាវីការពារសិទ្ធិជនជាប់ចោទធ្វើសេចក្តីសន្និដ្ឋានថា កូនក្តីខ្លួនបានឆ្លើយសារភាពនូវទង្វើរបស់ខ្លួន ហេតុដូច្នេះសុំឲ្យក្រុមប្រឹក្សាផ្តន្ទាទោសកូនក្តីរបស់ខ្លួនតាមមាត្រា ៣៥៣ និងមាត្រា ៣៥៦ នៃក្រមព្រហ្មទណ្ឌវិញ ។

៥-ជនជាប់ចោទនិយាយសម្តីចុងក្រោយថា សុំឲ្យក្រុមប្រឹក្សាបន្ធូរបន្ថយទោស ។

<u>ហេតុដូច្នេះ</u>

<u>វិនិច្ឆ័យសេចក្តី</u>

១-ទទួលពាក្យបណ្តឹងឧទ្ធរណ៍លេខ ១៦៦ ចុះថ្ងៃទី ២៨-០២-២០១៣ របស់ជនជាប់ចោទឈ្មោះ [redacted] សុគង់ ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ តែបដិសេធចោលដោយផ្ទុយនឹងគតិច្បាប់។

២-តម្កល់សាលក្រមព្រហ្មទណ្ឌលេខ ០៩ "កប៤" ចុះថ្ងៃទី ៣១-០១-២០១៣ របស់សាលាដំបូងរាជធានីភ្នំពេញ ទុកជាបានការ ។

៣-បន្តការឃុំខ្លួនជនជាប់ចោទ តាមច្បាប់ ។

៤-សាលដីកានេះជំនុំជម្រះនៅថ្ងៃទី ១៨-១២-២០១៣ ចំពោះមុខជនជាប់ចោទ និងប្រកាសជាសាធារណៈនៅថ្ងៃទី ៣១-១២-២០១៣ ។

ទុកសិទ្ធិឲ្យប្តឹងសាទុក្ខតាមកំណត់ច្បាប់ ៕

**សេចក្តីនេះ** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ទ្រង់ត្រាស់បង្គាប់មកមន្ត្រីទទួលបន្ទុកអនុវត្តសាលដីកា ស្ថាប័នមានសមត្ថកិច្ចគ្រប់ថ្នាក់ គ្រប់តំណែង និងកងកម្លាំងប្រដាប់អាវុធ ជួយសហការអនុវត្តសាលដីកានេះ ឲ្យបានសម្រេច ប្រសិនបើមានសំណូមពរត្រឹមត្រូវតាមច្បាប់។

| ក្រឡាបញ្ជី | ចៅក្រមប្រឹក្សា | ប្រធានក្រុមប្រឹក្សាជំនុំជម្រះ |
|---|---|---|
| ហត្ថលេខា [redacted] | ហត្ថលេខា [redacted] | ហត្ថលេខា [redacted] |

---

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម

ភ្នំពេញ ថ្ងៃទី 21 ខែ 4 ឆ្នាំ ២០១៤

បានឃើញ

ប្រធានសាលាឧទ្ធរណ៍

[redacted]

ក្រឡាបញ្ជី

[redacted]



Scanned with CamScanner